**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៣ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅៈ

- ធ្វើឲ្យមានឯកភាពនីយកម្មនៃប្រព័ន្ធអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់នូវការទទួលស្គាល់លើលទ្ធផលសិក្សាដែលបានបញ្ចប់តាមកម្រិតគុណវុឌ្ឍិនីមួយៗ ប្រកបដោយសង្គតិភាពជាតិ
- បង្កើតច្រកបត់បែន ដែលបង្កភាពងាយស្រួលដល់អ្នកសិក្សាក្នុងការផ្លាស់ប្តូររវាងផ្នែកឧត្តមសិក្សា និងផ្នែកបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងរវាង ផ្នែកទាំងពីរជាមួយនឹងទីផ្សារការងារ តាមរយៈការផ្តល់នូវមូលដ្ឋានសម្រាប់ការទទួលស្គាល់ការសិក្សាដែលមានពីមុន រួមមានការផ្ទេរក្រេឌីត និងការទទួលស្គាល់លើបទពិសោធ និងសមត្ថភាពបច្ចុប្បន្ន
- ផ្តល់ភាពបត់បែនទៅតាមគោលបំណងផ្សេងៗគ្នានៃការអប់រំ និងការបណ្តុះបណ្តាល
- លើកទឹកចិត្តដល់ការធ្វើវឌ្ឍនកម្មចំណេះដឹងនិងជំនាញ តាមរយៈការអប់រំ និងការបណ្តុះបណ្តាល ដោយកែលម្អឱ្យមានភាពច្បាស់លាស់នូវការជ្រើសរើសគុណវុឌ្ឍិ ការកំណត់ផលសម្រេច និងលើកកម្ពស់ការសិក្សាពេញមួយជីវិត
- ជំរុញការផ្តល់គុណភាពលើការបណ្តុះបណ្តាលឧត្តមសិក្សា បច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈគុណវុឌ្ឍិ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គល ទីកន្លែងការងារ និងវិជ្ជាជីវៈ រួមចំណែកជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- លើកកម្ពស់ការទទួលស្គាល់គុណវុឌ្ឍិ ដែលចេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្រិតជាតិ និងអន្តរជាតិ និង
- សម្រួលដល់ការចល័តកម្លាំងពលកម្មនៅក្នុងតំបន់។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើគ្រប់ទម្រង់នៃឧត្តមសិក្សា និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

ខ្លឹមសារទាំងស្រុងនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

គ្រប់គ្រឹះស្ថានសិក្សាដែលកំពុងដំណើរការបណ្តុះបណ្តាលបច្ចុប្បន្ន មានរយៈពេលមួយ (០១)ឆ្នាំ ដើម្បីកែលម្អការអប់រំ និងការបណ្តុះបណ្តាលរបស់ខ្លួន ឱ្យស្របតាមលក្ខខណ្ឌដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

គ្រឹះស្ថានសិក្សាដែលទើបចាប់ផ្តើមបើកដំណើរការបណ្តុះបណ្តាល ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ មុននឹងដំណើរការបណ្តុះបណ្តាល។

**មាត្រា ៦.-**

ការគ្រប់គ្រងលើការអនុវត្ត និងអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យអប់រំ និងស្ថាប័នទទួលស្គាល់គុណភាពអប់រំ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ